Public Disclosure Authorized

WORLD BANK GROUP

# អនាគតការងារនៅប្រទេសកម្ពុជា៖ តំណភ្ជាប់ទៅនឹងសេដ្ឋកិច្ចនាថ្ងៃខាងមុខ

## ការងារ គឺជាធាតុផ្សំសំខាន់មួយនៅក្នុងភាពជោគជ័យនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា

បច្ចុប្បន្ន មានការងារចំនួន៨លានការងារក្នុងប្រទេសកម្ពុជា ហើយ៨០ភាគរយនៃពលរដ្ឋពេញវ័យអាយុលើសពី១៥ឆ្នាំឡើងទៅ កំពុងធ្វើការដែលចំនួននេះគឺច្រើនជាង ៦២,៥ ភាគរយនៃជនពេញវ័យកំពុងធ្វើការនៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ទៅទៀត។ ចំនួនពលរដ្ឋកម្ពុជាដែលធ្វើការក្នុងវិស័យឯកជនមានប្រាក់ឈ្នួល បានកើនពី ១,១លាននាក់ក្នុងឆ្នាំ២០០៩ ដល់២,៦លាននាក់ក្នុងឆ្នាំ២០១៤។ យ៉ាងណាក៏ដោយពីរក្នុងចំណោមបីនាក់ គឺជាអ្នកធ្វើការនៅស្រែចម្ការ ដែលជាការងារបែបប្រពៃណីនិងគ្មានប្រាក់ឈ្នួល ឬក៏ធ្វើការក្នុងសហគ្រាសឬអាជីវកម្មជាលក្ខណៈគ្រួសារ។

## កម្ពុជាចាំបាច់ត្រូវធ្វើការកែទម្រង់ជាក់លាក់ច្រើន ដើម្បីធានាឱ្យមានការងារកាន់តែច្រើន កាន់តែល្អ និងកាន់តែបរិយាប័ន្នសម្រាប់អនាគតវែងឆ្ងាយទៅមុខទៀត

ជាមូលដ្ឋាន កម្ពុជាចាំបាច់ត្រូវធ្វើឱ្យផ្នែកទាំងពីរនៃសេដ្ឋកិច្ចកាន់តែមានភាពប្រសើរ និងកាន់តែធ្វើសមាហរណកម្មគ្នាឱ្យបានខ្លាំងក្លាថែមទៀត។ ផ្នែកទាំងពីរនោះមានវិស័យនាំចេញ ដែលជាបណ្តុំក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស (FDI) និងវិស័យក្នុងស្រុក ដែលផ្តុំឡើងដោយសហគ្រាសគ្រួសារ(HHEs) និងសហគ្រាសខ្នាតតូចនិងមធ្យម (SMEs)។ ទន្ទឹមគ្នានេះដែរ ពលករកម្ពុជាក៏ចាំបាច់ត្រូវខិតខំបង្កើតជំនាញ និងសមត្ថភាពរបស់ខ្លួនថែមទៀត ដើម្បីតាមចាប់យកឱកាសនានាដែលអាចនឹងកើតមានឡើង នៅពេលដែលវិស័យទាំងពីរនេះនៃសេដ្ឋកិច្ច មានភាពប្រកួតប្រជែងកាន់តែខ្លាំងក្លាថែមទៀត (រូប)។

**កម្ពុជានឹងត្រូវតែធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យវិស័យនាំចេញទទួលបានតម្លៃបន្ថែមកាន់តែខ្ពស់ ដើម្បីឈានទៅដណ្តើមការងារ និងគុណប្រយោជន៍ឱ្យបានកាន់តែច្រើនពីការចូលរួមនៅក្នុងខ្សែចង្វាក់តម្លៃសកល (GVCs).** ពិតណាស់ ការងារនៅក្នុងក្រុមហ៊ុននាំចេញមានតួនាទីគន្លឹះនាំមកនូវជោគជ័យក្នុងការអភិវឌ្ឍរបស់កម្ពុជា ប៉ុន្តែក្រុមហ៊ុនទាំងនេះ នៅមានសក្តានុពលបង្កើតផលចំណេញកាន់តែធំធេងទៀតនៅឡើយសម្រាប់ពលករ។ ពីចន្លោះឆ្នាំ២០១០ ដល់២០១៥ មួយភាគបីនៃ  ការងារមានប្រាក់ឈ្នួលទាំងអស់ គឺស្ថិតនៅក្នុងក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស ។នៅក្នុងឆ្នាំ២០១៤ ប្រាក់ឈ្នួលដែលបង់ទៅឱ្យពលករដែលបម្រើការងារផ្ទាល់ក្តី ឬដោយប្រយោលក្តីនៅតាមបណ្តាក្រុមហ៊ុននាំចេញ មានទំហំស្មើនឹង១៥ភាគរយនៃផ.ស.ស (ឬ ២,៦បីលានដុល្លារអាមេរិក)។ យ៉ាងណាក៏ដោយ សកម្មភាពធុរកិច្ចនាំចេញដែលកំពុងមាននៅកម្ពុជា ច្រើនតែជាប្រភេទនាំចេញ ដែលផ្តល់ប្រាក់ឈ្នួលទាប មានតម្លៃបន្ថែមទាប ហើយប្រើពលករតិចជាង ប្រសិនបើប្រៀបធៀបទៅនឹងក្រុមហ៊ុននាំចេញក្នុងប្រទេសដែលមានស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នានេះទៅទៀត។

**ចាំបាច់ត្រូវមានគោលនយោបាយមួយចំនួន ដើម្បីបង្កអំណោយផលឱ្យ HHEs និង SMEs លូតលាស់បាន ហើយក្លាយខ្លួនជាប្រភពគួរឱ្យពឹងផ្អែកបានក្នុងការផ្តល់ការងារល្អៗដល់ពលរដ្ឋ។** ក្រុមហ៊ុនក្នុងស្រុកមានចំនួនច្រើនជាងក្រុមហ៊ុនដែលមានម្ចាស់ជាបរទេស ក៏ប៉ុន្តែវាច្រើនតែមានទំហំតូច ហើយជួលកម្មករធ្វើការជាមធ្យមតែ៨នាក់ប៉ុណ្ណោះក្នុងមួយក្រុមហ៊ុន ប្រៀបទៅនឹង១២៤នាក់ជាមធ្យមនៅក្នុងក្រុមហ៊ុន FDI។ នេះមកពីដោយសារតែបរិយាកាសធុរកិច្ចក្នុងស្រុក ខ្វះភាពងាយស្រួលជួយគាំទ្រឱ្យសហគ្រិនអាចចាប់ផ្តើមធុរកិច្ច និងពង្រីកអាជីវកម្មរបស់ខ្លួនបាន។ ឧទាហរណ៍ មានតែ២៥ភាគរយនៃក្រុមហ៊ុនក្នុងស្រុកប៉ុណ្ណោះ ដែលទទួលបានឥណទានពីស្ថាប័នហិរញ្ញវត្ថុ ហើយមានតែ៦ភាគរយនៃសហគ្រាសខ្នាតតូចទេដែលបានចុះបញ្ជី ដោយសារតែថ្លៃចំណាយលើការចុះបញ្ជីនេះវាខ្ពស់ពេក។

**ការតភ្ជាប់បណ្តាញគ្នារវាងក្រុមហ៊ុន FDI និងក្រុមហ៊ុនក្នុងស្រុកត្រូវតែមានភាពស៊ីជម្រៅថែមទៀត ដើម្បីឈានទៅបង្កើតឱកាសធុរកិច្ចឱ្យកាន់តែច្រើនសម្រាប់ពលករក្នុងស្រុក។** ក្រុមហ៊ុនក្នុងស្រុកមានការតភ្ជាប់តិចតួចណាស់ជាមួយក្រុមហ៊ុន FDI ហើយដោយសារហេតុនេះ ក៏មិនសូវទាញបានគុណប្រយោជន៍ពីការលូតលាស់របស់ក្រុមហ៊ុន FDI ដែរ ។មានតែ២៥ភាគរយនៃធាតុចូល និងការផ្គត់ផ្គង់សរុបសម្រាប់រោងចក្រកាត់ដេរប៉ុណ្ណោះ ដែលត្រូវបានជាវពីក្រុមហ៊ុនក្នុងស្រុក។ ផ្ទុយទៅវិញ វិស័យកាត់ដេរនៅប្រទេសវៀតណាមជាវធាតុចូល និងការផ្គត់ផ្គង់នានាពីក្រុមហ៊ុនក្នុងស្រុក ក្នុងបរិមាណ៦០ភាគរយ បង់ក្លាដេស៦២ភាគរយ និងឥណ្ឌា ១០០ភាគរយ រៀងៗខ្លួន។

**ទាំងនិស្សិត ទាំងពលករកម្ពុជា ចាំបាច់ត្រូវបង្កើនការអប់រំ និងជំនាញរបស់ខ្លួន ដើម្បីមានសមត្ថភាពប្រកួតជាមួយពលករនៅប្រទេសស្រដៀងគ្នាក្នុងការដណ្តើមយកការងារប្រកបដោយគុណភាពខ្ពស់ៗ។** ពលករកម្ពុជានៅខ្វះជំនាញ ដែលចាំបាច់សម្រាប់ទទួលបានប្រភេទការងារដែលការកែទម្រង់ក្នុងវិស័យក្រុមហ៊ុនFDI និងក្រុមហ៊ុនក្នុងស្រុក នឹងនាំមកជាមួយនៅថ្ងៃខាងមុខ ។ក្នុងចំណោមពលរដ្ឋគ្រប់អាយុធ្វើការ មានតែ១៣ភាគរយប៉ុណ្ណោះបានរៀនចប់ថ្នាក់ទី១២។ សព្វថ្ងៃនេះកុមារកម្ពុជាអាយុ៤ឆ្នាំមួយនាក់ ត្រូវបានគេរំពឹងទុកថានឹងរៀនបានគ្រប់៩,៥ឆ្នាំកន្លះ ប៉ុន្តែកម្រិតរៀនចេះរបស់គេនឹងមានសមមូលត្រឹមតែ ៦,៩ឆ្នាំប៉ុណ្ណោះ។ នៅក្នុងឆ្នាំ២០១៦ក្រុមហ៊ុននាំចេញ៣៧,៦ភាគរយបានលើកបញ្ហាកម្លាំងពលកម្មដែលគ្មានការអប់រំគ្រប់គ្រាន់ ថាជាឧបសគ្គចម្បងគេសម្រាប់ធុរកិច្ច។ ស្ថានភាពនេះ ធ្វើឱ្យពលកម្មមានផលិតភាពទាប ហើយធ្វើឱ្យមានការពឹងផ្អែកលើការនាំចេញផលិតផលប្រើអតិពលកម្មដែលវាងាយរងគ្រោះណាស់ពីសំណាក់ស្វ័យប្រវត្តិកម្មរបស់បច្ចេកវិទ្យា។

### គោលនយោបាយទាំងប្រាំពីរសម្រាប់ការងារ កាន់តែរីកចម្រើន និងកាន់តែប្រសើរឡើង

